Hattha Bank

Subsidiary of krungsri bank

A member of MUFG, a global financial group

# របាយការណ៍ត្រីមាសទី១

ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២១

## ព័ត៌មានហិរញ្ញវត្ថុសង្ខេប

| ស្ថានភាពហិរញ្ញវត្ថុ | ត្រីមាសទី១ឆ្នាំ២០២១ | ២០២០ | ២០១៩ |
|---|---|---|---|
| ទ្រព្យសកម្មសរុប (លានរៀល) | ៦ ៨៧២ ១១៦ | ៦ ៣៧០ ៨៥០ | ៤ ៩៩៩ ៣២៣ |
| បំណុលសរុប (លានរៀល) | ៥ ៧៦៥ ៨១៣ | ៥ ៣២០ ៦២៥ | ៤ ១៩១ ០០៦ |
| មូលធនសរុប (លានរៀល) | ១ ១០៦ ៣០២ | ១ ០៥០ ២២៦ | ៨០៨ ៣១៧ |
| **លទ្ធផលហិរញ្ញវត្ថុ** | **ត្រីមាសទី១ឆ្នាំ២០២១** | **ត្រីមាសទី១ឆ្នាំ ២០២០** | **ត្រីមាសទី១ឆ្នាំ ២០១៩** |
| ចំណូលសរុប (លានរៀល) | ២១៤ ៥១៥ | ១៧៩ ៥៩៥ | ១៣២ ៧៨៧ |
| ចំណេញ/(ខាត)មុនបង់ពន្ធ (លានរៀល) | ៥៧ ៣៨៥ | ៣៥ ៥៣២ | ៣០ ៩៩២ |
| ចំណេញ/(ខាត)សុទ្ធក្នុងការិយបរិច្ឆេទ(លានរៀល) | ៤៦ ១៩៨ | ២៨ ២២០ | ២៤ ០៩៩ |
| លទ្ធផលលម្អិតក្នុងការិយបរិច្ឆេទ (លានរៀល) | ៥៧ ៩៤២ | ១២ ៩៥២ | ២៣ ៩៤១ |
| **អនុបាតហិរញ្ញវត្ថុ** | **ត្រីមាសទី១ឆ្នាំ២០២១** | **២០២០** | **២០១៩** |
| អនុបាតសាធនភាព (ភាគរយ) | ១៨,៤ | ១៧,៨ | ១៩,៤ |
| អនុបាតបំណុលធៀបនឹងមូលធន (ភាគរយ) | ៥២១ | ៥០៧ | ៥១៨ |
| អនុបាតសន្ទនីយភាព (ភាគរយ) | ១៥៣,៨ | ១៣១,០ | ១១៣,៩ |
| អនុបាតឥណទានមិនដំណើរការ[1] (ភាគរយ) | ១,១៩ | ១,៣១ | ០,៣០ |
| អនុបាតបញ្ញើឥណទាន (ភាគរយ) | ៥៨,២ | ៥៩,៩ | ៥៧,០ |
| | **ត្រីមាសទី១ឆ្នាំ២០២១** | **ត្រីមាសទី១ឆ្នាំ ២០២០** | **ត្រីមាសទី១ឆ្នាំ ២០១៩** |
| អនុបាតចំណេញភាពធៀបនឹងទ្រព្យសកម្ម (ភាគរយ) | ០,៦៧ | ០,៥៦ | ០,៦១ |
| អនុបាតចំណេញភាពធៀបនឹងមូលធន (ភាគរយ) | ៤,១៨ | ២,៨ ៨ | ៣,៤៦ |
| អនុបាតលទ្ធភាពបង់ការប្រាក់ (ភាគរយ) | ១៦៦ | ១៥១ | ១៥៧ |



[1] និយមន័យរបស់ធនាគារជាតិនៃកម្ពុជា

# ក្រាហ្វិកអំពីព័ត៌មានហិរញ្ញវត្ថុសង្ខេប






# សមាសភាពក្រុមប្រឹក្សាភិបាល



លោក Dan HARSONO
ប្រធានក្រុមប្រឹក្សាភិបាល



លោកឧកញ៉ា ហួត អៀងតុង
អភិបាល



កញ្ញា Duangdao WONGPANITKRIT
អភិបាល



អ្នកស្រី Voranuch DEJAKAISAYA
អភិបាល



លោក Chandrashekar S.K.
អភិបាល



លោក Wanchairabin JITWATTANATAM
អភិបាល



លោក ឡូញ ហៃ
អភិបាលឯករាជ្យ



លោក ឌី ដាវុឌ្ឍ
អភិបាលឯករាជ្យ



លោក ប៉ាក សេរីវឌ្ឍនា
អភិបាលឯករាជ្យ

# សេចក្តីថ្លែងរបស់ប្រធានក្រុមប្រឹក្សាភិបាល

ទិដ្ឋភាពអាជីវកម្មជាទូទៅ មានលក្ខណៈវិជ្ជមាន ជាពិសេសក្នុងរយៈពេល២ ខែដើមឆ្នាំដំបូងនៃឆ្នាំនេះ ប៉ុន្តែជាអកុសល ព្រឹត្តិការណ៍ផ្ទុះឆ្លងសហគមន៍កាលពីថ្ងៃទី២០ ខែកុម្ភៈ វាបានរំខានដល់សកម្មភាពដំណើរការអាជីវកម្មហើយវាត្រូវបានគេប៉ាន់ស្មានថា នឹងបន្តអូសបន្លាយផលប៉ះពាល់រហូតដល់ត្រីមាសទី២ ហេតុនេះ នៅពេលដែលជំងឺរាតត្បាតជាសកលនេះ នៅតែបន្តបង្កការគំរាមកំហែងដល់ប្រតិបត្តិការអាជីវកម្ម នោះវាបានបង្ខំឱ្យធនាគារធ្វើសកម្មភាពដោយរហ័សរហួនក្នុងការការពារហានិភ័យ និងតម្រូវឱ្យមានសកម្មភាពសម្រេចចិត្ត ដើម្បីធានាថា យើងការពារកម្មករនិយោជិតទាំងអស់ និងផ្តល់ការគាំទ្រដល់អតិថិជនរបស់យើងឱ្យបានទាន់ពេលវេលា។

ធនាគារ ហត្ថា ម.ក បានសម្រេចលទ្ធផលគួរជាទីគាប់ចិត្តក្នុងត្រីមាសទី១ ឆ្នាំ២០២១នេះ រួមមានៈ ផលប័ត្រឥណទានបានកើនឡើងដល់ចំនួន ១ ៤១២ លានដុល្លារអាមេរិក ដោយបានកើនឡើង៧% បើធៀបនឹងត្រីមាសមុន សមតុល្យប្រាក់បញ្ញើសន្សំ បានកើនឡើងដល់ចំនួន ៨២១ លានដុល្លារអាមេរិក ដោយកើនឡើង ៤% បើធៀបនឹងត្រីមាសមុន ហើយឥណទានមិនដំណើរការគឺ ០,៩០% ដោយសារផលប៉ះពាល់ពីជំងឺកូវីដ១៩ រីឯអនុបាតសាធនភាពមានចំនួន ១៨,៤% ខ្ពស់ជាងការកំណត់របស់និយ័តករ។ ធនាគារ ក្រុងស្រី គ្រោងនឹងផ្តល់ថវិកា និងដើមទុន បន្ថែមទៀតដើម្បីពង្រឹងភាពរឹងមាំខាងមូលធនរបស់ធនាគារ ហត្ថា ម.ក នៅត្រីមាសទី ២ ហើយករណីនេះ នឹងធានាបានថាធនាគារនៅតែបន្តដំណើរការយ៉ាងល្អ នៅក្នុងបរិយាកាសផុយស្រួយនេះ។

នៅជំណាច់ត្រីមាសទី១ ធនាគារ ហត្ថា ម.ក បានផ្តល់ការគាំទ្រដល់អតិថិជនតាមរយៈ ការរៀបចំឥណទានសារឡើងវិញ ជូនដល់អតិថិជនជាង ១៤ ០០០ នាក់ ស្មើនឹងចំនួនទឹកប្រាក់ប្រហែលជិត $១៤០ លានដុល្លារអាមេរិក ហើយធនាគារ ក៏បានធ្វើទំនើបកម្មលើសេវាធនាគារចល័តរបស់ខ្លួន ដោយទទួលបានចំនួន៤៥% ស្មើនឹងចំនួនអ្នកប្រើប្រាស់ជាង ២៣ ០០០ នាក់។ យើងមានគោលបំណងជំរុញ និងទាញយកផលចំណេញពីធនាគារឌីជីថល ដើម្បីផ្តល់ទាំងភាពងាយស្រួល និងទាំងសុវត្ថិភាពដល់អតិថិជនរបស់ខ្លួន។

ជាមួយនឹងបញ្ហាប្រឈមនាពេលបច្ចុប្បន្ននេះ ខ្ញុំសូមជូនពរឱ្យអ្នកទាំងអស់គ្នាមានសុវត្ថិភាព និងរឹងមាំក្នុងការដោះស្រាយស្ថានការណ៍នេះ ហើយយើងសង្ឃឹមថា នឹងបន្តដំណើរក្នុងត្រីមាសទី២ ប្រកបដោយការប្រុងប្រយ័ត្នដើម្បីធានាបាននូវលទ្ធផលល្អ និងគួរជាទីពេញចិត្ត។

កាលបរិច្ឆេទ៖ ថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ២០២១
ហត្ថលេខា និង ត្រា




លោក Dan HARSONO
ប្រធានក្រុមប្រឹក្សាភិបាល

## សេចក្តីថ្លែងរបស់ប្រធានអគ្គនាយក

ក្នុងរយៈពេលបីខែនៃដើមឆ្នាំ២០២១ គណៈគ្រប់គ្រង និងបុគ្គលិកទាំងអស់គ្នារបស់ធនាគារ ហត្ថា ម.ក បាន ខិតខំប្រឹងប្រែងអស់ពីកម្លាំងកាយចិត្ត ដើម្បីសម្រេចឲ្យននូវផែនការហិរញ្ញវត្ថុ និងប្រតិបត្តិការដែលបានកំណត់។ ទោះបីជាស្ថានភាពសេដ្ឋកិច្ចប្រទេសកម្ពុជា ក៏ដូចជាស្ថានភាពសេដ្ឋកិច្ចរបស់ពិភពលោកទាំងមូលទទួលរងនូវផលប៉ះពាល់ដោយការរីករាលដាលនៃជំងឺកូវីដ១៩ ក៏ដោយ ធនាគារ ហត្ថា ម.ក បានធ្វើប្រតិបត្តិការ អាជីវកម្មប្រកដដោយទំនុកចិត្ត និងប្រកបដោយទទួលខុសត្រូវខ្ពស់ រហូតសម្រេចបានលទ្ធផលជាផ្លែផ្កា។ ជាក់ស្តែង នៅក្នុងត្រីមាសទីមួយនៃឆ្នាំ ២០២១ កន្លងទៅនេះ ធនាគារ ហត្ថា ម.ក សម្រេចបាននូវលទ្ធផលល្អប្រសើរ និងគួរជាទីគាប់ចិត្ត។

គិតត្រឹមថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២១ លទ្ធផលសំខាន់ៗដែល ធនគារ ហត្ថា សម្រេចបានរួមមានៈ

-សមតុល្យប្រាក់កម្ចីចំនួន ១ ៤១២ ៦៩៤ 000 ដុល្លារអាមេរិក លើសផែនការ ១១,៧៧%

-ប្រាក់បញ្ញើសន្សំចំនួន ៨២១ ៥០៥ 000 ដុល្លារអាមេរិក លើសផែនការ ២០,៦៣%

-ឥណទានមិនដំណើរការគឺ 0,៩0% ល្អប្រសើរជាងផែនការចំនួន ១,៧៣%

ខ្ញុំពិតជាមានមោទនភាព ចំពោះលទ្ធផលដែលសម្រេចបានដូចខាងលើនេះ ហើយជួសមុខឲ្យគណៈគ្រប់គ្រងរបស់ធនាគារ ហត្ថា ម.ក ខ្ញុំសូមធ្វើការកោតសរសើរ និងវាយតម្លៃខ្ពស់ ព្រមទាំងថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះការខិតខំប្រឹងប្រែង តស៊ូអត់ធ្មត់ និងការប្តេជ្ញាចិត្តខ្ពស់របស់គណៈគ្រប់គ្រងគ្រប់ជាន់ថ្នាក់ និងបុគ្គលិកទាំងអស់ សម្រាប់ជោគជ័យយ៉ាងត្រចះត្រចង់នេះ ហើយបន្តការខិតខំប្រឹងប្រែងបន្ថែមទៀតដើម្បីបន្តដំណើរក្នុងការសម្រេចគោលដៅក្នុងឆ្នាំ២០២១។ ជាមួយគ្នានេះដែរ ខ្ញុំសូមថ្លែងអំណរគុណ ដល់អាជ្ញាធរអណាព្យាបាល អាជ្ញាធរមូលដ្ឋានគ្រប់លំដាប់ថ្នាក់ ក្រុមប្រឹក្សាភិបាល ព្រមទាំងអតិថិជនទាំងអស់របស់ធនាគារ ហត្ថា ម.ក ដែលតែងតែជួយគាំទ្រ និងបន្តគាំទ្រធនាគារ ហត្ថា ម.ក ឲ្យទទួលបានជោគជ័យដូចថ្ងៃនេះ។

ជាចុងក្រោយ ខ្ញុំសូមជូនពរដល់គណៈគ្រប់គ្រង និងបុគ្គលិកទាំងអស់ ឲ្យមានសុខភាពល្អ សំណាងល្អ រកទទួលទានមានបាន និងសុខដុមរមនានៅក្នុងគ្រួសារ។ ទន្ទឹមនឹងនេះផងដែរ ខ្ញុំក៏សូមអំពាវនាវឲ្យបុគ្គលិកគ្រប់ជាន់ថ្នាក់យកចិត្តទុកដាក់ និងមានការប្រុងប្រយ័ត្នខ្ពស់ក្នុងការការពារកុំឲ្យឆ្លងជំងឺកូវីដ១៩ ដោយអនុវត្តវិធានការ ៣កុំ ៣ការពារ តាមការណែនាំរបស់រាជរដ្ឋាភិបាលកម្ពុជា និងក្រសួងសុខាភិបាល ឲ្យបានខ្ជាប់ខ្ជួនជានិច្ច ដើម្បីសុវត្ថិភាពយើងទាំងអស់គ្នា។

កាលបរិច្ឆេទៈ ថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ២០២១

ហត្ថលេខា

លោកឧកញ៉ា ហួត អៀងតុង

ប្រធានអគ្គនាយក

# មាតិកា


ព័ត៌មានហិរញ្ញវត្ថុសង្ខេប ........ i

ក្រាហ្វិកអំពីព័ត៌មានហិរញ្ញវត្ថុសង្ខេប ........ ii

សមាសភាពក្រុមប្រឹក្សាភិបាល ........ iii

សេចក្តីថ្លែងរបស់ប្រធានក្រុមប្រឹក្សាភិបាល ........ iv

សេចក្តីថ្លែងរបស់ប្រធានអគ្គនាយក ........ v

ផ្នែកទី ១ ៖  ព័ត៌មានទូទៅពាក់ព័ន្ធនឹងបុគ្គលចុះបញ្ជីមូលបត្រ ........ ១

ក- អត្តសញ្ញាណបុគ្គលចុះបញ្ជីលក់មូលបត្រ ........ ១

ខ- លក្ខណៈនៃធុរកិច្ច ........ ១

គ- ព្រឹត្តិការណ៍សំខាន់ៗប្រចាំត្រីមាសរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ ........ ២

ផ្នែកទី ២ ៖  ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច ........ ៣

ក- លទ្ធផលប្រតិបត្តិការធុរកិច្ច ........ ៣

ខ- រចនាសម្ព័ន្ធចំណូល ........ ៤

ផ្នែកទី ៣ ៖  របាយការណ៍ហិរញ្ញវត្ថុដែលបានពិនិត្យឡើងវិញដោយសវនករឯករាជ្យ ........ ៥

ផ្នែកទី ៤ ៖  ការពិភាក្សា និងការវិភាគរបស់គណៈគ្រប់គ្រង ........ ៦

ក- ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ ........ ៦

ខ- កត្តាសំខាន់ៗដែលប៉ះពាល់លើផលចំណេញ ........ ៦

គ- ការប្រែប្រួលសំខាន់ៗលើការលក់ និងចំណូល ........ ៦

ឃ-ផលប៉ះពាល់នៃការប្តូររូបិយប័ណ្ណ អត្រាការប្រាក់ និងថ្លៃទំនិញ ........ ៦

ង- ផលប៉ះពាល់នៃអតិផរណា ........ ៧

ច- គោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ និងរូបិយវត្ថុ របស់រាជរដ្ឋាភិបាល ........ ៧

## ផ្នែកទី ១ ៖ ព័ត៌មានទូទៅពាក់ព័ន្ធនឹងបុគ្គលចុះបញ្ជីមូលបត្រ

ក- អត្តសញ្ញាណបុគ្គលចុះបញ្ជីលក់មូលបត្រ

| | |
|---|---|
| ឈ្មោះក្រុមហ៊ុនជាអក្សរខ្មែរ | ធនាគារ ហត្ថា ម.ក |
| ឈ្មោះជាអក្សរឡាតាំង | Hattha Bank Plc. |
| កូដស្តង់ដារ | KH20000718B4 |
| អាសយដ្ឋាន | អគារលេខ ៦០៦ ផ្លូវ២៧១ ភូមិសន្សំកុសល ៣ សង្កាត់បឹងទំពន់ ទី១ ខណ្ឌមានជ័យ រាជធានីភ្នំពេញ |
| លេខទូរស័ព្ទ | ០២៣ ៩៩៤ ៣០៤ |
| គេហទំព័រ | www.hatthabank.com |
| អ៊ីម៉ែល | info@hatthabank.com |
| លេខវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម | ០០០០៥៣៥៥ (ថ្ងៃទី០៣ ខែមេសា ឆ្នាំ២០០១) |
| លេខអាជ្ញាបណ្ណអាជីវកម្ម | ធ-៥៦ ចេញដោយ: ធនាគារជាតិនៃកម្ពុជាកាលបរិច្ឆេទ: ថ្ងៃទី០៥ ខែសីហា ឆ្នាំ២០២០ |
| សេចក្តីសម្រេចអនុញ្ញាត និងចុះបញ្ជីឯកសារផ្តល់ព័ត៌មាន | លេខ ១៦៥/១៨គ.ម.ក. កាលបរិច្ឆេទ: ថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៨ |
| តំណាងធនាគារ ហត្ថា ម.ក ដោយ | លោកឧកញ៉ា ហួត អៀងតុង |

ខ- លក្ខណៈនៃធុរកិច្ច

ធនាគារ ហត្ថា ម.ក គឺជាធនាគារមួយក្នុងចំណោមធនាគារឈានមុខផ្សេងទៀតនៅកម្ពុជា ដែលទទួលបានអាជ្ញាប័ណ្ណធ្វើប្រតិបត្តិការធនាគារពាណិជ្ជពី ធនាគារជាតិនៃកម្ពុជា និងក្រសួងពាណិជ្ជកម្ម ចាប់ពីថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០២០។ ជាមួយបទពិសោធន៍ក្នុងការបម្រើសេវាហិរញ្ញវត្ថុទៅកាន់ប្រជាជនកម្ពុជាអស់រយៈពេលជាង ២៦ឆ្នាំ ក្រោយការផ្លាស់ប្តូរមុខមាត់ថ្មីរបស់ខ្លួន ធនាគារ ហត្ថា ម.ក បានកែលម្អ និងដាក់ឱ្យប្រើប្រាស់បន្ថែមនូវសេវាកម្មហិរញ្ញវត្ថុជាច្រើនផ្សេងទៀតក្នុងនោះមានដូចជា៖ ការធ្វើឱ្យកាន់តែប្រសើរឡើងនូវសេវាធនាគារចល័ត (Hattha Mobile) ដាក់ឱ្យប្រើប្រាស់នូវសេវាផ្ទេរប្រាក់ឆ្លងធនាគារ សេវាឥណទានវិបារូបន៍ សេវាបញ្ញើសន្សំផលច្រើន (HYSA Flexi and HYSA Corporate) និងការត្រៀមខ្លួនក្នុងការផ្តល់ជូនសេវាធនាគារថ្មីៗផ្សេងទៀត បន្ថែមលើសេវាដែលមានស្រាប់ដូចជា៖ សេវាឥណទាន សេវាប្រាក់បញ្ញើសន្សំ សេវាផ្ទេរប្រាក់ក្នុងស្រុក សេវាអេធីអឹម សេវាបើកប្រាក់បៀវត្ស និងជាអ្នកណែនាំលក់សេវាធានារ៉ាប់រងផងដែរ។

គិតត្រឹម ខែ មីនា ឆ្នាំ ២០២១ សមតុល្យប្រាក់បញ្ញើសន្សំ របស់ ធនាគារ ហត្ថា ម.ក មានចំនួនជាង ៨២២ លានដុល្លារអាមេរិក ជាមួយនឹងចំនួនអតិថិជនប្រាក់បញ្ញើសន្សំ ២៧៧ ៣៦០ នាក់ និងផលប័ត្រឥណទានសរុបមាន ចំនួនប្រមាណ ១ ៤១២ លានដុល្លារអាមេរិក ដែលបម្រើអតិថិជន ចំនួន ១៨៩ ៤៨០ នាក់ តាមរយៈសាខាចំនួន ១៧៧ និងម៉ាស៊ីនអេធីអឹមចំនួន ១៣៧ទីតាំង នៅទូទាំងប្រទេស។

ធនាគារ ហត្ថាម.ក គឺជាបុត្រសម្ព័ន្ធរបស់ ធនាគារ ក្រុងស្រី។ ធនាគារ ក្រុងស្រី (ធនាគារ អាយុធ្យា ម.ក និង ក្រុមហ៊ុនជាបុត្រសម្ព័ន្ធ) គឺជាសម្ព័ន្ធហិរញ្ញវត្ថុធំជាងគេលំដាប់ទី៥ នៅក្នុងព្រះរាជាណាចក្រថៃ ដោយយោងលើទំហំទ្រព្យសកម្ម ផលប័ត្រឥណទាន និងប្រាក់បញ្ញើសន្សំ និងជាធនាគារមួយក្នុងចំណោមធនាគារ D-SIBs ចំនួនប្រាំ ដែលបានធ្វើប្រតិបត្តិការអាជីវកម្មជូនអតិថិជនរបស់ខ្លួនអស់រយៈពេល ៧៥ ឆ្នាំ មកហើយនៅក្នុងព្រះរាជាណាចក្រថៃ។ ធនាគារ ក្រុងស្រី គឺជាសមាជិកយុទ្ធសាស្ត្ររបស់សម្ព័ន្ធហិរញ្ញវត្ថុ MUFG ដែលជាសម្ព័ន្ធហិរញ្ញវត្ថុធំជាងគេបង្អស់នៅជប៉ុន ក៏ដូចជាសម្ព័ន្ធហិរញ្ញវត្ថុដ៏ធំមួយក្នុងចំណោមសម្ព័ន្ធហិរញ្ញវត្ថុធំៗផ្សេងទៀតនៅលើពិភពលោក។

### គ- ព្រឹត្តិការណ៍សំខាន់ៗប្រចាំត្រីមាសរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ

ដូចដែលយើងទាំងអស់គ្នាបានដឹងរួចមកហើយថា ការរីករាតត្បាតនៃជម្ងឺកូវីដ១៩ បានបង្កឱ្យមានផលលំបាកយ៉ាងខ្លាំងដល់សកម្មភាពអាជីវកម្មសំខាន់ៗជាច្រើនទាំងនៅក្នុងប្រទេសកម្ពុជាក៏ដូចជាពិភពលោកទាំងមូល។ ទោះជាយ៉ាងនេះក្តី ធនាគារ ហត្ថា ម.ក នៅតែបន្តប្រតិបត្តិការរបស់ខ្លួនយ៉ាងរឹងមាំ និងប្រកបដោយទំនុកចិត្តពីអតិថិជន សាធារណជន និងគ្រប់ភាគីពាក់ព័ន្ធ។ ស្របតាមគោលដៅអាជីវកម្មយូរអង្វែងរបស់ខ្លួន នៅក្នុងត្រីមាសទី១ ឆ្នាំ ២០២១ ធនាគារហត្ថាម.ក បានអនុវត្តក៏ដូចជាសម្រេចបាននូវសមិទ្ធផលសំខាន់ៗជាច្រើនដូចជា ធនាគារ ហត្ថា ម.ក ប្រកាសគម្រោងអគារការិយាល័យកណ្តាលថ្មី ដែលមានទំហំជាង ៤០ ០០០ ម៉ែត្រក្រឡា តាមបណ្តោយផ្លូវ៦០ម៉ែត្រ ដែលឆ្លុះបញ្ចាំងយ៉ាងច្បាស់ថាធនាគារ ហត្ថា ម.ក ទទួលបានជោគជ័យធំៗផ្ទួនៗគ្នា បន្ថែមពីលើការរីកចម្រើនឥតឈប់ឈរពីអាជីវកម្មរបស់ខ្លួន ពីព្រោះថាកាលពីចុងឆ្នាំ ២០២០ កន្លងមកនេះ ទទួលបានជោគជ័យយ៉ាងត្រចះត្រចង់ដោយបានកម្លាយខ្លួនពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ ទៅជាធនាគារពាណិជ្ជ ទោះបីជានៅក្នុងអំឡុងពេលដែលប្រទេសកម្ពុជាក៏ដូចជាពិភពលោកទាំងមូលកំពុងជួបនូវវិបត្តិកូវីដ១៩ក៏ដោយ។ ហើយជាក់ស្តែងក្នុងថ្ងៃនេះ ធនាគារ ហត្ថា ម.ក បានចុះហត្ថលេខា ដើម្បីសាងសង់អគារការិយាល័យកណ្តាលថ្មីរបស់ខ្លួនចំកណ្តាលបេះដូងនៃទីក្រុងភ្នំពេញ និងជាតំបន់ដែលពោរពេញទៅដោយសក្តានុពលក្នុងការអភិវឌ្ឍសេដ្ឋកិច្ច។

បន្ថែមលើនេះទៀត ដើម្បីរួមចំណែកដល់វិស័យកសិកម្មដែលជាវិស័យអាទិភាពមួយរបស់រាជរដ្ឋាភិបាល ធនាគារ ហត្ថា ម.ក សហការជាមួយក្រុមហ៊ុន ស៊ី អេស អេហ្គ្រីខលឌីវ័ល ឌីវេឡុបម៉ិន ជំរុញការអភិវឌ្ឍវិស័យកសិកម្មនៅកម្ពុជា ដែលកិច្ចសហការនេះគឺជាសក្ខីភាពថ្មីមួយបន្ថែមទៀតដើម្បីបង្ហាញពីការរួមចំណែកអភិវឌ្ឍវិស័យកសិកម្ម និងដើម្បីជំរុញប្រជាកសិករកម្ពុជាបង្កើនលទ្ធភាព សមត្ថភាព បច្ចេកទេស ចំណេះដឹង និងការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាទំនើបក្នុងការដាំដុះ និងប្រមូលកសិផលសម្រាប់ប្រើប្រាស់ក្នុងស្រុក និងនាំចេញទៅក្រៅប្រទេស ជាពិសេសជំរុញឱ្យមានការទទួលស្គាល់គុណភាពផលិតផលរបស់ប្រជាកសិករយើងលើឆាកអន្តរជាតិផងដែរ។

ព្រឹត្តិការណ៍សំខាន់មួយផ្សេងទៀតដែលសមស្របទៅនឹងការត្រៀមខ្លួនរបស់រាជរដ្ឋាភិបាលសម្រាប់សេដ្ឋកិច្ចឌីជីថល គឺថ្មីៗនេះ ធនាគារ ហត្ថា ម.ក បានដាក់ឱ្យប្រើប្រាស់នូវសេវាកម្មទូទាត់តាម QR កូដតាមរយៈសេវាធនាគារចល័តហត្ថា (Hattha Mobile) នៅក្នុងប្រទេសថៃឡង់ដ៍ ដែលក្នុងនេះ អតិថិជនរបស់ធនាគារ ហត្ថា ម.ក ដែលធ្វើដំណើរទៅប្រទេសថៃឡង់ដ៍ អាចធ្វើការទូទាត់ចំណាយផ្សេងៗជាប្រាក់រៀល ដោយគ្រាន់តែធ្វើការស្កេនQR កូដថៃ នៅតាមទីតាំងលក់ទំនិញជាង ៥ លាន កន្លែង នៅទូទាំងប្រទេសថៃឡង់ដ៍ តាមរយៈកម្មវិធីសេវាធនាគារចល័តហត្ថា (Hattha Mobile) នេះ។ ផលិតថ្មីនេះ នាំមកនូវបទពិសោធន៍ផ្តល់ជូនអតិថិជនកាន់តែប្រសើរ ក្នុងការកាត់បន្ថយបន្ទុកប្តូររូបិយប័ណ្ណរបស់អតិថិជនពីប្រាក់រៀល ទៅប្រាក់បាតថៃ និងការយកប្រាក់តាមខ្លួនទៅទូទាត់ចំណាយផ្សេងៗនៅប្រទេសថៃឡង់ដ៍។ ដូច្នេះ ជាមួយនឹងការដាក់ឱ្យប្រើប្រាស់នូវផលិតផលថ្មីមួយនេះ ធនាគារ ហត្ថា ម.ក បាននឹងកំពុងផ្តល់ឱ្យអតិថិជនរបស់ខ្លួន នូវជម្រើសទូទាត់ប្រកបដោយភាពងាយស្រួល លឿនរហ័ស និងមានសុវត្ថិភាពជាងមុន ដែលជួយកាត់បន្ថយហានិភ័យទាក់ទងនឹងការយកប្រាក់តាមខ្លួនច្រើន ប្រាក់ក្លែងក្លាយ ការខ្វះខាតសាច់ប្រាក់ ឬក៏លើសសាច់ប្រាក់មិនចាំបាច់ ជាដើម។

## ផ្នែកទី ២ ៖ ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច

### ក- លទ្ធផលប្រតិបត្តិការធុរកិច្ច

| លទ្ធផលសម្រេចបានសំខាន់ៗ | ផែនការ | លទ្ធផលសម្រេចបាន |
|---|---|---|
| ផ្នែកសេវាឥណទាន | | |
| ចំនួនគណនីសេវាឥណទាន | ១៨០ ៧២២ | ១៨៩ ៤៨០ |
| ឥណទាននៅក្នុងដៃអតិថិជន (ពាន់ដុល្លារអាមេរិក) | ១ ២៦៣ ៩៤៤ | ១ ៤១២ ៦៩៤ |
| ផ្នែកសេវាប្រាក់បញ្ញើសន្សំ | | |
| ចំនួនគណនីសេវាប្រាក់បញ្ញើសន្សំ | ២៧២ ៨៦៧ | ២៧៧ ៣៦០ |
| សមតុលប្រាក់បញ្ញើសន្សំ (ពាន់ដុល្លារអាមេរិក) | ៦៨០ ៩៨៩ | ៨២១ ៥០៥ |
| ផ្នែកសេវាកម្មផ្សេងៗទៀត | | |
| ចំនួនអ្នកប្រើប្រាស់កាតអេធីអឹម | ៦៧ ២៦៧ | ៥២ ៨៦៨ |
| ចំនួនអ្នកប្រើប្រាស់សេវាធនាគារចល័ត | ១៩ ៥៣២ | ២៣ ៦៨៧ |
| ការណែនាំភ្ញៀវឱ្យប្រើប្រាស់សេវាធានារ៉ាប់រងខ្នាតតូច (ដុល្លារអាមេរិក) | ១៥១ ៩៣៣ | ៨០ ៨៥០ |
| ការណែនាំភ្ញៀវឱ្យប្រើប្រាស់សេវាធានារ៉ាប់រងអាយុជីវិតឥណទាន (ដុល្លារអាមេរិក) | ១ ៩៩៧ ៥៧២ | ២ ៦០១ ៤៦៣ |
| ផ្នែកប្រតិបត្តិការសំខាន់ផ្សេងៗទៀត | | |
| ចំនួនការិយាល័យ | ១៧៧ | ១៧៧ |

| | | |
|---|---|---|
| ចំនួនអេធីអឹម | ១៥២ | ១៣៧ |
| ចំនួនបុគ្គលិក | ៥ ៦៩៨ | ៥ ៤៦៧ |

## ខ- រចនាសម្ព័ន្ធចំណូល

| ល.រ | ប្រភពចំណូល | ត្រីមាសទី១ ឆ្នាំ ២០២១ | | ត្រីមាសទី១ ឆ្នាំ២០២០ | | ត្រីមាសទី១ ឆ្នាំ ២០១៩ | |
|---|---|---|---|---|---|---|---|
| | | ចំនួនទឹកប្រាក់ (លានរៀល) | ភាគរយ | ចំនួនទឹកប្រាក់ (លានរៀល) | ភាគរយ | ចំនួនទឹកប្រាក់ (លានរៀល) | ភាគរយ |
| ១ | ចំណូលការប្រាក់ | ២០៧ ០៣៣ | ៩៦,៥ | ១៧៣ ៤៧៣ | ៩៦,៦ | ១២៧ ២០១ | ៩៥,៨ |
| ២ | ចំណូលផ្សេងៗ | ៧ ៤៨២ | ៣,៥ | ៦ ១២២ | ៣,៤ | ៥ ៥៨៦ | ៤,២ |
| ចំណូលសរុប | | ២១៤ ៥១៥ | | ១៧៩ ៥៩៥ | | ១៣២ ៧៨៧ | |

## ផ្នែកទី ៣ ៖ របាយការណ៍ហិរញ្ញវត្ថុដែលបានពិនិត្យឡើងវិញដោយសវនករឯករាជ្យ

សូមពិនិត្យមើលរបាយការណ៍លម្អិតនៅក្នុងឧបសម្ព័ន្ធដែលបានភ្ជាប់មកជាមួយ។

## ផ្នែកទី ៤ ៖ ការពិភាក្សា និងការវិភាគរបស់គណៈគ្រប់គ្រង

ការពិភាក្សា និងការវិភាគខាងក្រោមនេះ គឺជាការពិភាក្សាលើលទ្ធផលនៃប្រតិបត្តិការ និងស្ថានភាពហិរញ្ញវត្ថុ ពីគណៈគ្រប់គ្រងរបស់ ធនាគារ ហត្ថា ម.ក ដោយផ្អែកទៅលើរបាយការណ៍ហិរញ្ញវត្ថុគិតត្រឹម ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២១ហើយដែលបានត្រួតពិនិត្យឡើងវិញដោយសវនករឯករាជ្យ គិតត្រឹមថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២១។

របាយការណ៍ហិរញ្ញវត្ថុទាំងនេះរបស់ធនាគារ ហត្ថា ម.ក ត្រូវបានរៀបចំឡើងដោយអនុលោមទៅតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ។

គណៈគ្រប់គ្រងធ្វើការពិភាក្សា និងវិភាគលើសមាសធាតុសំខាន់នៃរបាយការណ៍ហិរញ្ញវត្ថុ និងកត្តាសំខាន់ៗដែលបាន ជះឥទ្ធិពលទៅលើប្រាក់ចំណេញរបស់ធនាគារ ហត្ថា ម.ក តែប៉ុណ្ណោះ ។

### ក- ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ

#### ការវិភាគចំណូល

ធនាគារ ហត្ថា ម.ក មានចំណូល ២ប្រភេទធំៗគឺ ចំណូលពីការប្រាក់ និងចំណូលផ្សេងៗ

| | |
|---|---|
| **ចំណូលពីការប្រាក់រួមមាន៖** ចំណូលការប្រាក់សុទ្ធដែលទទួលបានពីការផ្តល់ឥណទានដល់ អតិថិជន និងពីការដាក់ប្រាក់បញ្ញើនៅតាមបណ្តា ធនាគារនានា។ ហើយចំណូលទាំងនេះត្រូវទទួលស្គាល់ជាប្រចាំខែ។ | **ចំណូលផ្សេងៗរួមមាន៖** កម្រៃណែនាំសេវាធានារ៉ាប់រង កម្រៃផ្ទេរ-ប្រាក់ ចំណូលកម្រៃផ្សេងៗ ចំណូលបានមកពីការប្រមូលឥណទានលុបចោល ចំណេញពីការប្តូរប្រាក់ ។ល។ |

ចំណូលការប្រាក់ ជាចំណូលដ៏ធំនិងសំខាន់សម្រាប់ ធនាគារ ហត្ថា ម.ក ដែលមានរហូតដល់ ៩៦,៥% នៃចំណូលសរុប។

### ខ- កត្តាសំខាន់ៗដែលប៉ះពាល់លើផលចំណេញ

នាដំណាច់ការិយបរិច្ឆេទថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២១នេះ គណៈគ្រប់គ្រងរបស់ ធនាគារ ហត្ថា ម.ក យល់ថាផលប៉ះពាល់ជាអវិជ្ជនៃការរីករាលដាលកូវីដ១៩ ត្រូវបានគ្រប់គ្រងបានយ៉ាងល្អនៅក្នុងត្រីមាសនេះ ជាលទ្ធផលធ្វើឱ្យប្រាក់ចំណេញមានការកើនឡើងធៀបនឹងត្រីមាសមុន។លទ្ធផលនេះ មកពីការកើនឡើង នៃចំណូលការប្រាក់ និង ថយចុះនៃការចំណាយលើឱនភាពតម្លៃនៃ ឧបករណ៍ហិរញ្ញវត្ថុ។

### គ- ការប្រែប្រួលសំខាន់ៗលើការលក់ និងចំណូល

នាដំណាច់ការិយបរិច្ឆេទថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២១នេះ គណៈគ្រប់គ្រងរបស់ ធនាគារ ហត្ថា ម.ក យល់ថាការលក់ និងចំណូលមានការកើនឡើងនៅក្នុងដំណាក់កាលកូវីដ១៩នេះ។

### ឃ- ផលប៉ះពាល់នៃការប្តូររូបិយប័ណ្ណ អត្រាការប្រាក់ និងថ្លៃទំនិញ

ធនាគារ ហត្ថា ម.ក បានកត់ត្រាបញ្ជីគណនេយ្យដោយប្រើប្រាស់រូបិយប័ណ្ណគោលគឺ ប្រាក់ដុល្លារអាមេរិក។ ប្រតិបត្តិការជា រូបិយវត្ថុប្រាក់រៀល និងរូបិយប័ណ្ណប្រាក់ថៃបាត ត្រូវបានប្តូរទៅជា រូបិយប័ណ្ណគោលតាមអត្រាប្តូរប្រាក់នាកាលបរិច្ឆេទនៃប្រតិបត្តិការនោះ។ ចំណេញ និង ខាតដែលបណ្តាលមកពីការទូទាត់ប្រតិបត្តិការបែបនេះ ការប្តូរទ្រព្យសកម្មនិងបំណុល រូបិយប័ណ្ណបរទេស ត្រូវបានកត់ត្រា នៅក្នុងរបាយការណ៍លទ្ធផលលម្អិត។

### ង- ផលប៉ះពាល់នៃអតិផរណា

ធនាគារ ហត្ថា ម.ក មិនបានកែប្រែអត្រាការប្រាក់ដោយផ្អែកតាមការប្រែប្រួលនៃអតិផរណាទេ ពោលគឺផ្អែកទៅលើស្ថានភាព ប្រកួតប្រជែងជាក់ស្តែងនៅក្នុងទីផ្សារ ហើយនៅតែរក្សាបាននូវចេរភាពហិរញ្ញវត្ថុយ៉ាងល្អប្រសើរ។

### ច- គោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ និងរូបិយវត្ថុ របស់រាជរដ្ឋាភិបាល

នៅក្នុងត្រីមាសទី១ ឆ្នាំ២០២១ នេះ រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជានៅតែបន្តអនុវត្តវិធានការដែលមានស្រាប់សំខាន់ៗជាច្រើនដើម្បីធានាឱ្យបាននូវកំណើន និងស្ថិរភាពសេដ្ឋកិច្ចជាតិ ដូចជាការបន្តផ្តល់ហិរញ្ញប្បទាន គាំទ្រនិយោជិតដែលត្រូវបានព្យួរការងារ (ក្នុងវិស័យកាត់ដេរ វាយនភណ្ឌ ស្បែកជើង និងទេសចរណ៍) និងគ្រួសារដែលមានប័ណ្ណក្រីក្រ ដើម្បីឆ្លើយតបទៅនឹងការកាត់បន្ថយផលប៉ះពាល់អវិជ្ជមាននៃការរីករាលដាលជំងឺកូវីដ១៩។ គោលនយោបាយពាក់ព័ន្ធផ្សេងៗទៀតរួមមាន៖

នៅថ្ងៃទី១១ ខែកម្ភៈ ឆ្នាំ២០២១ ធនាគារជាតិនៃកម្ពុជាបានស្នើគ្រប់ធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទាំងអស់ផ្អាកការបែងចែកភាគលាភចំពោះប្រាក់ចំណេញទៅឱ្យភាគទុនិកសម្រាប់ឆ្នាំ២០២០ ដែលជាវិធានការក្នុងការការពារកំណើន ស្ថិរភាព និងភាពប្រាកដប្រជានៃវិស័យហិរញ្ញវត្ថុនេះទប់ទល់នឹងផលប៉ះពាល់បង្កឡើងដោយការរីករាលដាលជំងឺកូវីដ១៩។ ជាមួយនេះ ធនាគារជាតិនៃកម្ពុជាស្នើឱ្យគ្រប់គ្រឹះស្ថានទាំងអស់ផ្អាកការបែងចែកភាគលាភចំពោះប្រាក់ចំណេញរបស់គ្រឹះស្ថានក្រោយធ្វើសវនកម្ម ឆ្នាំ២០២០ និង រៀបចំយុទ្ធសាស្ត្រចាកចេញ (Exit Strategy) សមស្របបន្ទាប់ពីការអនុគ្រោះធានាពីធនាគារជាតិនៃកម្ពុជា ត្រូវបានបញ្ចប់។

នៅថ្ងៃទី២២ ខែមីនា ឆ្នាំ២០២១ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងធនាគារជាតិនៃកម្ពុជា នៅក្នុងសេចក្តីប្រកាសរួមមួយ បានអំពាវនាវ និងលើកទឹកចិត្តដល់ក្រុមហ៊ុនអភិវឌ្ឍអចលនវត្ថុទាំងអស់បន្ធូរបន្ថយស្ថានភាពទូទាត់របស់អតិថិជនរបស់ខ្លួនអំឡុងពេលនៃការរីករាលដាលយ៉ាងខ្លាំងនៃជំងឺកូវីដ១៩ នេះ។ យោងតាមសេចក្តីប្រកាសរួមនេះ ដែលស្ថិតក្នុងបរិបទនៃការរីករាលដាលនៃជំងឺកូវីដ១៩ រាជរដ្ឋាភិបាលបានអំពាវនាវដល់ក្រុមហ៊ុនអភិវឌ្ឍអចលនវត្ថុទាំងអស់ពិនិត្យមើលលើការបន្ធូរបន្ថយលក្ខខណ្ឌបង់រំលស់ទៅតាមស្ថានភាពជាក់ស្តែងរបស់អតិថិជនក្នុងគោលបំណងធ្វើឱ្យបន្ទុកហិរញ្ញវត្ថុរបស់អតិថិជនដែលបានទិញអចលនទ្រព្យ មានភាពធូរស្រាលមួយកម្រិត។

បន្ថែមពីលើនេះ នៅថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២១ រាជរដ្ឋាភិបាលបានចេញសេចក្តីណែនាំ របស់រាជរដ្ឋាភិបាលកម្ពុជាអំពីវិធានការបន្ថែម ដើម្បីបន្តគ្រប់គ្រងផលប៉ះពាល់លើវិស័យសំខាន់ៗនៃសេដ្ឋកិច្ច នៅក្នុងបរិការណ៍នៃវិបត្តិ ការស្តារ និងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជា ក្នុងអំឡុង និងក្រោយពីវិបត្តិនៃជំងឺកូវីដ១៩។ ដោយការរីករាលដាលនៃជំងឺកូវីដ១៩ នៅបន្តជះឥទ្ធិពលអវិជ្ជមានដល់សង្គមសេដ្ឋកិច្ចក្រោមស្មារតីបុរេសកម្ម និងការទទួលខុសត្រូវខ្ពស់រាជរដ្ឋាភិបាលបានដាក់ចេញនូវវិធានការចាំបាច់ជាបន្តបន្ទាប់ក្នុងគោលបំណងទប់ស្កាត់ការរីករាលដាលនៃជំងឺនេះ និងបន្តជួយរក្សាលំនឹងអាជីវកម្មធុរកិច្ចក្នុងវិស័យដែលទទួលរងផលប៉ះពាល់ធ្ងន់ធ្ងរ។ នាពេលបច្ចុប្បន្ន ប្រទេសមួយចំនួនបាននឹងកំពុងអភិវឌ្ឍវ៉ាក់សាំងបង្ការជំងឺកូវីដ១៩ ព្រមទាំងបានសម្រេចចាក់វ៉ាក់សាំងជូនប្រជាពលរដ្ឋរបស់ខ្លួនផងដែរ។ ដូចប្រទេសមួយចំនួនទៀត ប្រទេសកម្ពុជា ក៏បាននឹងកំពុងស្វែងរក ព្រមទាំងបញ្ជាទិញវ៉ាក់សាំងពីគ្រប់ប្រភពដែលមាន ទៅតាមតម្រូវការចាំបាច់ជាក់ស្តែង និងបានរៀបចំយុទ្ធនាការចាក់វ៉ាក់សាំងជូនប្រជាពលរដ្ឋរៀងខ្លួនផងដែរ។ យ៉ាងណាក៏ដោយ ទោះបីជាយុទ្ធនាការនេះ បាននឹងកំពុងប្រព្រឹត្តិទៅដោយរលូន ក៏មិនមានន័យថា យើងទាំងអស់គ្នាអាចការពារការឆ្លងរីករាលដាលនៃជំងឺកូវីដ១៩ បាន១០០% ហើយស្ថានភាពសង្គម-សេដ្ឋកិច្ច អាចវិលត្រលប់ទៅរកប្រក្រតីភាពវិញដូចមុនក្នុងរយៈពេលដ៏ខ្លីបាននោះឡើយ។ ជាក់ស្តែង "**ព្រឹត្តិការណ៍សហគមន៍២០ កុម្ភៈ ២០២១**" បានបណ្តាលឱ្យករណីវិជ្ជមាននៃជំងឺកូវីដ១៩ កើនឡើងយ៉ាងគំហុក និងគួរឱ្យព្រួយបារម្ភ ព្រមទាំងបានឆក់យកអាយុជីវិតអ្នកឆ្លងជំងឺកូវីដ១៩ ជនជាតិ

ខ្មែរមួយចំនួនផងដែរ។ បន្ថែមពីលើនេះ គ្រួសារក្រីក្រ និងងាយរងគ្រោះមួយចំនួនធំ ក៏នៅតែបន្តប្រឈមនឹងបញ្ហាលំបាកផ្សេងៗក្នុងជីវភាពរស់នៅប្រចាំថ្ងៃ។ បន្ទាប់ពីបានពិនិត្យពិច័យ និងថ្លឹងថ្លែងយ៉ាងល្អិតល្អន់លើទិដ្ឋភាពសង្គម-សេដ្ឋកិច្ច បន្ទុកសុខាភិបាល ស្ថានភាពពាណិជ្ជកម្ម និងវិនិយោគ ទាំងក្នុងក្របខណ្ឌសកល តំបន់ និងប្រទេស រាជរដ្ឋាភិបាលបានសម្រេចដាក់ចេញនូវវិធានការបន្ថែម ជុំទី៨ ក្នុងគោលបំណង៖ (១) កាត់បន្ថយផលប៉ះពាល់មកលើស្ថានភាពសង្គម-សេដ្ឋកិច្ច ដែលបណ្តាលមកលើការឆ្លងនៃព្រឹត្តិការណ៍សហគមន៍ ២០ កុម្ភៈ ២០២១ (២) បន្តសុពលភាពនៃវិធានការដែលបានដាក់ចេញនាពេលកន្លងមក ដែលនឹងផុតកំណត់សម្រាប់ការអនុវត្តក្នុងពេលឆាប់ៗខាងមុខ (៣) បន្តដាក់ចេញ និងអនុវត្តវិធានការទ្រទ្រង់ និងស្តារអាជីវកម្ម និងធុរកិច្ច ឱ្យងើបឡើងវិញ ដើម្បីចូលរួមជំរុញកំណើនសេដ្ឋកិច្ច នៅក្នុងបរិការណ៍ក្រោយវិបត្តិនៃជំងឺកូវិដ១៩ និង (៤) បន្តជួយទំនុកបម្រុងដល់ជីវភាពប្រចាំថ្ងៃរបស់គ្រួសារក្រីក្រ និងងាយរងគ្រោះ តាមរយៈកម្មវិធីឧបត្ថម្ភសាច់ប្រាក់។ វិធានការជុំទី៨ ដែលត្រូវបានរៀបចំឡើង ដោយមានការពិគ្រោះយោបល់យ៉ាងទូលំទូលាយជាមួយគ្រប់តួអង្គពាក់ព័ន្ធរួមមាន៖ វិធានការបន្តជួយវិស័យកាត់ដេរវាយនភណ្ឌ ស្បែកជើង ផលិតផលធ្វើដំណើរ កាបូប និងវិស័យទេសចរណ៍, វិធានការបន្តជួយវិស័យអាកាសចរណ៍ និងកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះ។

## ហត្ថលេខារបស់អភិបាល ធនាគារ ហត្ថា ម.ក

កាលបរិច្ឆេទ៖ ១៣ ខែ ឧសភាឆ្នាំ២០២១
បានអាន និងឯកភាព

លោក ឡូញ ហៃ
អភិបាលឯករាជ្យ

កាលបរិច្ឆេទ៖ ១៣ ខែ ឧសភាឆ្នាំ២០២១
បានអាន និងឯកភាព

លោកបណ្ឌិត ឌី ដាវុឌ្ឍ
អភិបាលឯករាជ្យ

Hattha Bank

Subsidiary of krungsri bank

A member of MUFG, a global financial group